ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល
លេខ......៧៥.......ស.ភ.រ

# សេចក្តីជូនដំណឹង

**សាលាភូមិន្ទរដ្ឋបាល** សូមជូនដំណឹងដល់មន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា សម្រាប់ឆ្នាំ២០២៤ សាលានឹងរៀបចំជ្រើសរើសសិក្ខាកាមសម្រាប់វគ្គបណ្តុះបណ្តាលរយៈពេលខ្លី **សិក្សាតាមប្រព័ន្ធអនឡាញ** ដែលវគ្គសិក្សាមានដូចជា វគ្គ ៖

១. ការគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ (សិក្សាថ្ងៃសៅរ៍ និងអាទិត្យ រយៈពេល ១៥ម៉ោង)
២. ការគ្រប់គ្រង និងអភិវឌ្ឍស្ថាប័ន (សិក្សាថ្ងៃចន្ទ ពុធ និងសុក្រ រយៈពេល ១៥ម៉ោង)
៣. ការគ្រប់គ្រងយុទ្ធសាស្ត្រ (សិក្សាថ្ងៃសៅរ៍ និងអាទិត្យ រយៈពេល ១៥ម៉ោង)

❖ មន្ត្រីរាជការដែលនឹងទទួលការបណ្តុះបណ្តាលសម្រាប់វគ្គនីមួយៗ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖
- ជាមន្ត្រីរាជការស៊ីវិល យោធិន ឬមន្ត្រីនគរបាលជាតិ ដែលបានតាំងស៊ប់រួចក្នុងក្របខណ្ឌ

មន្ត្រីរាជការដែលមានបំណងសិក្សាវគ្គបណ្តុះបណ្តាលខាងលើ សូមអញ្ជើញចុះឈ្មោះសិក្សាតាមប្រព័ន្ធអនឡាញដោយចូលទៅកាន់តំណភ្ជាប់ https://lms.era.gov.kh/qrlink/3V ឬតាមរយៈ QR code ខាងក្រោម គិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ ការទទួលចុះឈ្មោះចូលរៀននឹងធ្វើឡើងជាបន្តបន្ទាប់សម្រាប់ឆ្នាំ២០២៤ ហើយសាលានឹងចាប់ផ្តើមបើកថ្នាក់សិក្សាពេលចំនួនសិក្ខាកាមគ្រប់ចំនួនតាមគោលការណ៍របស់សាលា។

សិក្ខាកាមត្រូវភ្ជាប់ឯកសារចូលក្នុងប្រព័ន្ធរួមមាន៖
- រូបថតទើបថតថ្មី ទំហំ៤X៦ (ផ្ទៃខាងក្រោយពណ៌ស)
- អត្តសញ្ញាណប័ណ្ណ ឬសំបុត្រកំណើត
- លិខិតតាំងស៊ប់ក្នុងក្របខណ្ឌ ឬលិខិតតែងតាំងក្នុងមុខតំណែង។

<u>បញ្ជាក់៖</u>

ក. ការទទួលបានសិទ្ធិចូលសិក្សា ៖ បន្ទាប់ពីពិនិត្យត្រឹមត្រូវលើលក្ខខណ្ឌរបស់បេក្ខជនរួចរាល់ សាលានឹងផ្តល់ព័ត៌មានត្រឡប់ជូនបេក្ខជនតាមរយៈអ៊ីម៉ែលរបស់សាមីខ្លួនដែលបានដាក់ពាក្យ ដើម្បីបង់ថ្លៃសេវារដ្ឋបាលសុំសិទ្ធិចូលសិក្សាតាម រយៈគណនីធនាគាររបស់សាលាភូមិន្ទរដ្ឋបាល និងទទួលបានបង្កាន់ដៃសុំសិទ្ធិចូលរៀន។

ខ. ថ្លៃសេវារដ្ឋបាលដើម្បីទទួលបានសិទ្ធិចូលសិក្សាមានកំណត់ក្នុងអ៊ីម៉ែលសាមីខ្លួន។

ថ្ងៃ សុក្រ ៦រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០២៤
**សាលាភូមិន្ទរដ្ឋបាល**

https://lms.era.gov.kh/qrlink/3V

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងទៅតាមលេខទូរសព្ទ និងតេឡេក្រាមខាងក្រោម (រៀងរាល់ថ្ងៃ និងម៉ោងធ្វើការ) ៖
- លោក ហេង វិបុល ៖ ០១១ ៨១២ ៥១១
- លោក ជាន់ តារា ៖ ០១០ ៨៤៧ ៧៧៦

https://lms.era.gov.kh/qrlink/3V